# សេចក្តីថ្លែងការណ៍របស់ដៃគូអភិវឌ្ឍន៍

## របៀបវារៈទី IIA: ការអភិវឌ្ឍន៍វិស័យឯកជន

**ថ្លែងដោយឯកឧត្តម ម៉ាសាហ៊្វុមី គូរ៉ូគី (Masafumi Kuroki) ឯកអគ្គរាជទូតជប៉ុន**

**ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**

**តំណាងដៃគូអភិវឌ្ឍន៍ នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាទី៣**

**ភ្នំពេញ ថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១០**

សូមគោរព ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន!

ប្រទេសកម្ពុជាសំរេចបាននូវទសវត្សរ៍នៃកំណើនសេដ្ឋកិច្ចដ៏គួរអោយកត់សំគាល់ ចាប់តាំងពីទទួលបាននូវសន្តិភាព ហើយបច្ចុប្បន្ននេះកំពុងរំលេចខ្លួនចេញពីផលវិបាកនៃវិបត្តិសេដ្ឋកិច្ចសកលនាពេលថ្មីៗនេះ ។ វិបត្តិនេះបានគូសបញ្ជាក់អំពីតំរូវការដើម្បីបន្តធ្វើពិពិធកម្មធនធាននៃកំណើន កសាងនូវការប្រៀបធៀបផលប្រយោជន៍របស់កម្ពុជា ដូចជាជីធ្លី មតិតប្រវត្តិសាស្ត្រ កម្លាំងពលកម្ម និង ធនធានធម្មជាតិរបស់ខ្លួន និង ចលនាអោយយកមកប្រើប្រាស់កាន់តែច្រើនឡើងនូវប្រាក់សន្សំ ។ វិបត្តិនេះក៏បានប្រមូលផ្តុំផងដែរនូវតំរូវការដើម្បីបង្កើតឡើងនូវការងារ ក្នុងមួយឆ្នាំៗចំនួន២៥០.០០០សំរាប់យុវជន-យុវនារី ចំនួនមួយភាគបួនលាននាក់ ដែលនឹងចូលទៅក្នុងទីផ្សារការងារ ជាមួយនឹងការកើនឡើងនូវមុខជំនាញ និងក្តីសង្ឃឹម ។

បរិស្ថាននៃការវិនិយោគមួយដ៏ត្រឹមត្រូវ គឺមានអត្ថន័យជាសារវន្តដើម្បីទាក់ទាញវិនិយោគិនបរទេស ក៏ដូចជាវិនិយោគិនក្នុងស្រុក ជាពិសេសឆ្ពោះទៅរកវិស័យដែលជួយដល់ការបង្កើតឱកាសការងារច្រើន អភិវឌ្ឍន៍សក្តានុពលសំរាប់ការនាំចេញរបស់កម្ពុជា និង គោរពទៅដល់និរន្តរភាពនៃការគ្រប់គ្រងធនធានធម្មជាតិរបស់កម្ពុជា ។ បរិស្ថានមួយបែបនេះត្រូវរួមបញ្ចូលផងដែរនូវក្របខណ្ឌច្បាប់ និង បទបញ្ញត្តិដ៏ល្អមួយ ជាមួយនឹងអភិបាលកិច្ចសមស្របដើម្បីធានាអោយបាននូវការប្រព្រឹត្តិតាមដោយត្រឹមត្រូវ មានតម្លៃសមរម្យអាចលៃលកបាន និង ហេដ្ឋារចនា

សម្ពន្ធ័ដែលងាយស្រួលចូលទៅដល់បាន និង កម្លាំងពលកម្មដែលប្រកបដោយសុខភាព និង មានការអប់រំល្អ ។ ប្រទេសកម្ពុជាមានភាពជាម្ចាស់មួយទៀត នោះគឺគុណភាពនៃការសន្ទនាជាមួយវិស័យឯកជនតាមរយៈវេទិកា រាជរដ្ឋាភិបាល-វិស័យឯកជន ។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និង ក្រុមការងាររបស់វេទិកានេះនៅក្នុងការបង្កើតឡើងនូវឱកាសដើម្បីកំណត់អត្តសញ្ញាណ និងឆ្លើយតបទៅនឹងអ្វី ដែលជាឧបសគ្គដល់ដំណើរការអភិវឌ្ឍន៏វិស័យឯកជន។ ដៃគូអភិវឌ្ឍន៍សង្ឃឹមថា វេទិការាជរដ្ឋាភិបាល-វិស័យឯកជននឹងបន្តជាគោលនយោបាយប្រកបដោយប្រសិទ្ធិភាពមួយសំរាប់អោយវិស័យឯកជនធ្វើការពិភាក្សាជាមួយរាជរដ្ឋាភិបាល ។

ដៃគូអភិវឌ្ឍន៏នឹងបន្តផ្តល់ជំនួយ ODA ដើម្បីគាំទ្រដល់ការធ្វើហិរញ្ញប្បទានហេដ្ឋារចនាសម្ពន្ធ័ផ្នែករឹង និង ផ្នែកទន់ ដើម្បីអភិវឌ្ឍន៏វិស័យឯកជន ។ ការរួមចំណែករបស់ដៃគូអភិវឌ្ឍន៏ក៏មានរួមបញ្ចូលផងដែរនូវភាពអនុគ្រោះពិសេសដើម្បីឈានចូលទីផ្សារ ដែលប្រទេសកម្ពុជាកំពុងមានអំណរសាទរកាន់តែខ្លាំងឡើង ។ ដៃគូអភិវឌ្ឍន៏មានបំណងជំរុញរាជរដ្ឋាភិបាលអោយប្រើប្រាស់យន្តិការ "ជំនួយ-សំរាប់-ពាណិជ្ជកម្ម" ដើម្បីធានាប្រសិទ្ធិភាពជាអតិបរិមារបស់ជំនួយឧបត្ថម្ភទាំងឡាយដែលទាក់ទិនដល់វិស័យពាណិជ្ជកម្ម ។ ដៃគូអភិវឌ្ឍន៏មួយចំនួនក៏កំពុងគាំទ្រយ៉ាងសកម្មផងដែរដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនៅក្នុងការទាក់ទាញវិនិយោគិនបរទេស ។

ដោយកសាងនៅលើបញ្ហាប្រឈម និង កាលានុវត្តិភាពទាំងនេះ យើងខ្ញុំមានសំណួរមួយចំនួនដើម្បីដាក់ជូនពិភាក្សាៈ

- តើរាជរដ្ឋាភិបាលគិតថានឹងកំណត់នូវគោលនយោបាយជាក់លាក់ និង វិធានការណ៍ជាក់ស្តែងអ្វីខ្លះដើម្បីសំរួលដល់ការធ្វើពិពិធកម្ម និង ការបង្កើនវិស័យឧស្សាហកម្ម? ឧទាហរណ៏ តើរាជរដ្ឋាភិបាលមើលឃើញថាតំបន់សេដ្ឋកិច្ចពិសេសមានតួនាទីយ៉ាងណា - ដែលត្រូវបានបង្កើតឡើងនៅកម្ពុជាជាច្រើនឆ្នាំកន្លងមកហើយ ប៉ុន្តែហាក់បីដូចជាមិនទាន់ទទួលបាននូវសក្តានុពលរបស់គេដូចដែលបានរំពឹងទុកនោះ - ហើយតើជំនួយអ្វីខ្លះដែលដៃគូអភិវឌ្ឍន៏អាចផ្តល់ជូនបានដើម្បីបន្តធ្វើឧស្សាហូបនីយកម្មសេដ្ឋកិច្ច?
- នៅពេលដែលយើងទទួលស្គាល់អំពីតួនាទីជាសារវន្តរបស់សាលាបឋមសិក្សានោះ ប្រពន្ធ័អប់រំក៏មានតួនាទីសំខាន់ផងដែរនៅក្នុងការបណ្តុះបណ្តាលធនធានមនុស្សដែលចាំបាច់សំរាប់បំរើអោយវិស័យឯកជនចំរុះ និង

ទំនើបមួយ ដូចជាអ្នកបច្ចេកទេស វិស្វករ និង អ្នកគ្រប់គ្រងកំរិតមធ្យម ដើម្បីអោយត្រូវគ្នាទៅនឹងសេចក្តីត្រូវការរបស់វិស័យឧស្សាហកម្មនាពេលអនាគតទាំងបរិមាណ ក៏ដូចជា គុណភាព ។ តើអ្វីខ្លះទៅជាអាទិភាពរបស់រាជរដ្ឋាភិបាលនៅក្នុងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជានៅក្នុងវិស័យអប់រំបច្ចេកទេស និង បច្ចេកវិទ្យា ហើយតើជំនួយអ្វីខ្លះដែលដៃគូអភិវឌ្ឍន៍អាចផ្តល់ជូនបាន?

- តើរាជរដ្ឋាភិបាលវាយតម្លៃយ៉ាងដូចម្តេច មិនត្រឹមតែចំពោះផលកម្រៃដែលទទួលបានត្រឡប់មកវិញនោះទេ តែក៏ចំពោះហានិភ័យផងដែរ ពីការធ្វើសម្បទានជាច្រើនបែប (មានដូចជាសម្បទានដីធ្លី-តំបន់សេដ្ឋកិច្ច-អភិវឌ្ឍន៍ទេសចរណ៍ ។ល។) ដើម្បីធានាថាសម្បទានទាំងនេះបានធ្វើអោយដល់កំរិតអតិបរិមានូវផលប្រយោជន៍រយៈពេលមធ្យម រហូតដល់រយៈពេលវែងរបស់ប្រទេសទាំងនៅក្នុងលក្ខខណ្ឌការងារ - បច្ចេកវិទ្យា -បរិស្ថាន និង ការអភិវឌ្ឍន៍សហគមន៍ ហើយតើជំនួយអ្វីខ្លះដែលដៃគូអភិវឌ្ឍន៍អាចផ្តល់ជូនបាន?
- តើរាជរដ្ឋាភិបាលនឹងប្រកាន់យកនូវវិធានការណ៍ជាក់លាក់អ្វីខ្លះដើម្បីធ្វើអោយងាយស្រួលដល់ដំណើរការធ្វើពាណិជ្ជកម្ម ក៏ដូចជា ធ្វើអោយងាយស្រួលដល់និតិវិធីដើម្បីទទួលបានអាជ្ញាបណ្ណ័ដែលត្រូវឆ្លងកាត់ពីក្រសួងមួយទៅក្រសួងមួយដូចដែលបានឯកភាពគ្នានៅឯវេទិការាជរដ្ឋាភិបាល-វិស័យឯកជនថ្មីៗនេះ ហើយតើជំនួយអ្វីខ្លះដែលដៃគូអភិវឌ្ឍន៍អាចផ្តល់ការគាំទ្របាន?